**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃពុធ ទី៣ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំសិក្ខាសាលាតាមប្រព័ន្ធវីដេអូ ដើម្បីផ្សព្វផ្សាយពីច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីការទូតកម្ពុជានៅតាមស្ថានតំណាងកម្ពុជានៅបរទេសទាំងអស់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមានការចូលរួមធ្វើបទ-អន្តរាគមន៍ដោយ **ឯកឧត្តម សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ថ្លែងនៅក្នុងពិធីបើកសិក្ខាសាលានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងក្រុមការងារនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានខិតខំប្រឹងប្រែងអស់រយៈពេល ៦ឆ្នាំ ក្នុងការសិក្សាស្រាវជ្រាវ និងតាក់តែងរហូតធ្វើឱ្យច្បាប់ស្តីពីវិនិយោគថ្មីនេះលេចចេញជារូបរាងឡើង។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានរំលេចពីបច្ច័យអវិជ្ជមាន ដែលកើតចេញពីវិបត្តិនៃជំងឺកូវីដ-១៩ និងសង្គ្រាមពាណិជ្ជកម្ម ដែលធ្វើឱ្យសេដ្ឋកិច្ចសកល និងលំហូរវិនិយោគផ្ទាល់ពីបរទេសទូទាំងពិភពលោកមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ឯការប្រកួតប្រជែងរបស់មហាអំណាចដែលធ្វើឱ្យប្រែប្រួលសណ្តាប់ធ្នាប់អន្តរជាតិ ក៏បានដាក់សម្ពាធដល់តំបន់អាស៊ី-ប៉ាស៊ីហ្វិក និងបានប៉ះពាល់ដល់មជ្ឈភាព និងសាមគ្គីភាពអាស៊ាន និងទំនាក់ទំនងរបស់អង្គការតំបន់នេះជាមួយដៃគូខាងក្រៅ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ជឿជាក់យ៉ាងមុតមាំថា ការដាក់ឱ្យប្រើនូវច្បាប់វិនិយោគថ្មីនេះ ត្រូវបានធ្វើឡើងចំពេលវេលាដែលកម្ពុជាត្រូវការស្តារឡើងវិញនូវសង្គម-សេដ្ឋកិច្ច ក្រោយវិបត្តិកូវីដ-១៩ និងធ្វើឱ្យកម្ពុជាក្លាយជាទិសដៅដ៏ទាក់ទាញមួយសម្រាប់វិនិយោគិន។ ការដាក់ឲ្យប្រើនូវច្បាប់ថ្មីនេះក៏ស្របពេលដែលរាជរដ្ឋាភិបាលសម្រេចឱ្យបើកដំណើរការសកម្មភាពសេដ្ឋកិច្ច និងប្រទេសឡើងវិញជាបណ្តើរៗ ដើម្បីទទួលស្វាគមន៍ភ្ញៀវទេសចរណ៍ និងវិនិយោគិនបរទេស ពិសេសទេសចរណ៍ចាក់វ៉ាក់សាំង និងការកំណត់គោលនយោបាយតំបន់ទេសចរណ៍សុវត្ថិភាព។

ទន្ទឹមនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ច្បាប់វិនិយោគថ្មីនេះនឹងដើរតួនាទីយ៉ាងសំខាន់ដល់ការអនុវត្ត**យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣** ឱ្យកាន់តែមាន



អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ប្រសិទ្ធភាព និងទទួលបានជោគជ័យ តាមរយៈស្ថានតំណាងកម្ពុជាប្រចាំនៅបរទេសទាំងអស់ដែលជាសេនាធិការរបស់ក្រសួងកបទ.សអ ក្នុងការកៀរគរដៃគូវិនិយោគថ្មីប្រកបដោយសក្តានុពលខ្ពស់ចូលមកប្រទេសកម្ពុជា។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ **សុខ ចិន្តាសោភា** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបានចូលរួមជ្រោមជ្រែងកិច្ចខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយច្បាប់ស្តីពីវិនិយោគថ្មីនេះជូនដល់ ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីការទូតកម្ពុជានៅតាមស្ថានតំណាងកម្ពុជានៅបរទេសទាំងអស់ ដែលជាយុទ្ធសាស្ត្រដ៏មុតស្រួចក្នុងការបង្ហាញពីកាលានុវត្តភាពនៅកម្ពុជាសំដៅទាក់ទាញការវិនិយោគប្រកបដោយគុណភាពបន្ថែម។ លើសពីនេះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហការជាប្រចាំរបស់ក្រសួងកបទ.សអ ព្រមទាំងស្ថានតំណាងកម្ពុជាប្រចាំនៅក្រៅប្រទេសទាំងអស់ ដែលជានិច្ចកាលតែងរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញវិនិយោគ និងផ្សព្វផ្សាយ ពីបរិស្ថានវិនិយោគនៅកម្ពុជាជូនដល់វិនិយោគិនបរទេស។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២១